## គោលការណ៍នីត្យានុកូលភាព (*Nullum Crimen Sine Lege*)

គោលការណ៍នេះ ចែងថា បុគ្គលនឹងត្រូវបានឲ្យទទួលខុសត្រូវ និងផ្តន្ទាទោស លុះត្រានៅពេលគាត់ប្រព្រឹត្តអំពើល្មើស អំពើនោះ ត្រូវបានចាត់ថាជាបទល្មើសព្រហ្មទណ្ឌតាមបទបញ្ញត្តិច្បាប់។ គោលការណ៍នេះ ជាច្បាប់សារធាតុ (substantive justice)។

អត្ថិភាពនៃគោលការណ៍ គឺក្នុងបំណងជំទាស់នឹងអំណាចបំពានរបស់ស្តេច (Magna Charta)។ រីឯអ្នកទស្សនៈវិទូដូចជា Montesquieu យល់ថាគោលការណ៍នេះ ដើម្បីកម្រិតអំណាចអ្នកដឹកនាំ និងធានាអំណាចសភា ព្រមទាំងតុលាការ។

តាមគោលការណ៍នេះ៖ ១. បទល្មើសព្រហ្មទណ្ឌ ត្រូវតែបានចែងជាលាយលក្ខអក្សរដោយច្បាប់។ ២. ច្បាប់ព្រហ្មទណ្ឌ ត្រូវតែចែងជាក់លាក់ (principle of specificity) ៣. វិធានព្រហ្មទណ្ឌ មិនត្រូវអនុវត្តប្រតិសកម្ម (Non-Retroaction) និង ៤. ការបកស្រាយតាមន័យសទិសភាព (analogy) ត្រូវហាមឃាត់។ ក្នុងន័យនេះ សម្រាប់ចំណុចទី១ ប្រទេសកំមុនឡ ដែលប្រើច្បាប់ធ្វើឡើងដោយចៅក្រម (judge-made law) មិនទំនងជាត្រឹមត្រូវពេញលេញទេ។ ភាពជាក់លាក់ ត្រូវសម្រាប់ធាតុផ្សំទាំងពីរនៃបទល្មើស (material element and *mens rea*)។ សម្រាប់ចំណុចទី៤ ករណីបកស្រាយ ហើយមានលទ្ធផលពីរផ្ទុយគ្នា អ្វីដែលផ្អៀងដល់ផលប្រយោជន៍ជនល្មើស ត្រូវតែប្រកាន់យក (favor rei)។

ក្នុងវិស័យព្រហ្មទណ្ឌអន្តរជាតិ វិធាននេះត្រូវបានប្រើប្រាស់ទូលាយ ដោយសំដៅការពារផលប្រយោជន៍សង្គមទាំងមូល ជាជាងប្រយោជន៍បុគ្គល ដែលជាផលប្រយោជន៍ដើមដំបូង ដែលគោលការណ៍នេះការពារ។ ដូចនេះ គោលការណ៍នេះ ត្រូវបានប្រើជំនួសដោយពាក្យ «ទ្រឹស្តីនៃភាពស្របច្បាប់តឹងតែង» (strict legality)។

គោលការណ៍នីត្យានុកូលភាព មានចែងក្នុងសន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិ ដូចជាមាត្រា១៥ នៃកតិកាសញ្ញាស្តីពីសិទ្ធិប្រជាពលរដ្ឋ ព្រមទាំងមានចែងក្នុងលក្ខន្តិកៈបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ (មាត្រា២២(១) នៃលក្ខន្តិកៈ ICC)

ដកស្រង់ពី Antonio Cassese, *Nullum Crimen Sine Lege*, the Oxford Companion to International Criminal Justice, 2009, pp. 438-441។